# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤៧១-៩៧

# អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ ភ្នំពេញ

**ផ្ញើរមក**

**លោក ព្រះរាជអាជ្ញាប្រចាំតុលាការខេត្ត ក្រុង និងលោកចៅក្រមស៊ើបអង្កេត**

**សូមជ្រាប។**

**កម្មវត្ថុ:** លិខិតឯកសារផ្សេងៗ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ។

ខ្ញុំបានសង្កេតឃើញកន្លងមកតាមរយៈសំណុំកុំរឿងផ្សេងៗ មានឯកសារជាភស្តុតាខ្លះដែលបញ្ជូនមកពីនគរបាលយុត្តិធម៌ ឬផ្តល់ឱ្យដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយសាក្សី ឬដោយជនត្រូវចោទ ដើម្បីយកមកដាក់ក្នុងសំណុំកុំរឿង បានត្រូវចាត់ពីសំណុំរឿង ដោយហេតុជួនកាលមកពីការច្រឡំចូលទៅក្នុងសំណុំរឿងដទៃផ្សេងទៀត ជួនកាលបណ្តាលមកពីការបំបាត់ត្រង់ៗតែម្តង ។ អំពើចុងក្រោយនេះជាអំពើប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ បញ្ញត្តិមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌ ចុះថ្ងៃទី១០ កញ្ញា ១៩៩២ ដែលអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវប៉ុន្តែការញែកកំហុសអាចប្រទះការពិបាកខ្លះដោយការទទួលបន្ទុកថែរក្សាសំណុំរឿងបានត្រូវផ្ទេរពីអស់លោកបុគ្គលិកមួយទៅមួយ ហើយការញែកនេះរឹងរឹតតែស្មុគស្មាញថែមទៀត កាលណាគ្មានការរៀបចំឱ្យទទួលខុសត្រូវតាំងពីមុនដំបូងឡើង ។

លិខិតទាំងឡាយអាចត្រូវបញ្ជូនមកតាមផ្លូវ ជួនកាលទទួលផ្ទាល់ដៃមានចុះហត្ថលេខាទទួលត្រឹមត្រូវ(១) តាំងពីអយ្យការ ពីមន្ទីរចៅក្រមស៊ើបអង្កេត ជួនកាលទៅដំណាក់កាលចៅក្រមជំនុំជម្រះ ប៉ុន្តែទម្លាប់អនុវត្តកន្លងមកលោកក្រឡាបញ្ជី ចៅក្រមជំនុំជម្រះម្នាក់ប៉ុណ្ណោះជាអ្នកធ្វើបញ្ជីរាយលិខិតនៃសំណុំរឿងទាំងស្រុងតាំងពីលេខ១ដល់លេខចុងក្រោយបញ្ចប់ ។ ទង្វើរបៀបនេះពុំមានន័យថា លោឲ្យក្រឡាបញ្ជីរូបនេះជាអ្នកទទួលខុសត្រូវលើលិខិតចាត់នេះទេ ព្រោះលិខិតដែលបាត់នោះអាចមានតាំងពីដំណាក់កាលទៅអយ្យការ ឬនៅមន្ទីរចៅក្រមស៊ើបសួរម្លេះ ។

ដើម្បីអាចញែកកំហុសក្នុងរឿងបាត់លិខិ ឬបំបាត់លិខិតភស្តុតាងនៃសំណុំរឿងទៅថ្ងៃមុខ ខ្ញុំសូមអស់លោកព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ជួយត្រួតពិនិត្យ និងជួយចាត់ចែងរៀបចំភារៈកិច្ចរបស់អស់លោកក្រឡាបញ្ជីឱ្យធ្វើបញ្ជីរាយលិខិតតាមស្ថាប័នបន្តបន្ទាប់ គឺពីអយ្យការ ពីចៅក្រមស៊ើបអង្កេត ដោយឡែកៗពីគ្នាដោយមានចុះលេខា និងហត្ថលេខាបំពេញ ហើយត្រូវចៀសវាងការចុះលេខ២ដង លុបក្រវេមក្រវាមលើលេខចុះ នៅចុងលិខិតដើម្បីចៀសវាងកង្វះសណ្តាប់ធ្នាប់ និងតម្រូវឱ្យមានការទទួលខុសត្រូវតទៅផង ។

គ្រប់ឯកសារ ភស្តុតាងទទួលយកមកដាក់ក្នុងសំណុំរឿង ត្រូវតែតាក់តែងជាភាសាខ្មែរ បើឯកសារដើមរៀបរៀងជាភាសាបរទេស ត្រូវឱ្យមានការបកប្រែជាភាសាខ្មែរជាមុនហើយស្រេចសឹមទទួល ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧

**អគ្គរដ្ឋអាជ្ញា**

**ហង់រ៉ូ រ៉ាគេន**

ចម្លងជូន
-ក្រសួងយុត្តិធម៌
-ប្រធានតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាបជាព័ត៌មាន